# សកម្មភាព និង ការរៀនសូត្រតាមបែបចូលរួម
Participatory Learning and Action

## ១. បែបបទនៃការរៀនរបស់មនុស្សពេញវ័យ

### ១.១. ការប្រៀបធៀបរវាង របៀបរៀនរបស់កុមារ និងមនុស្សចាស់

| | ការរៀន/បង្រៀនរបស់កុមារ | ការរៀន/បង្រៀនរបស់មនុស្សពេញវ័យ |
|---|---|---|
| តួនាទីជាស្នូលរបស់អ្នករៀន | • ធ្វើតាមតែការណែនាំ<br>• ទទួលយកដោយអសកម្ម<br>• ចាំតែទទួលព័ត៌មានពីគ្រូ<br>• ទទួលខុសត្រូវតិចតួចក្នុងដំណើរការនៃការរៀនសូត្រ ។ | • ផ្តល់គំនិតដោយផ្អែកលើបទពិសោធន៍ ។<br>• ពឹងពាក់គ្នាទៅវិញទៅមក<br>• ចូលរួមសកម្ម<br>• ទទួលខុសត្រូវក្នុងដំណើរការនៃការរៀនសូត្រ ។ |
| កត្តាលើកទឹកចិត្តក្នុងការរៀន | • **កត្តាខាងក្រៅ :** ( សង្គមតម្រូវ ឬគ្រួសារម៉ែឪ បងប្អូន បង្ខំ )<br>• អ្នករៀនមើលមិនសូវឃើញពីតំរូវការ ឬផលប្រយោជន៍ចំពោះមុខប៉ុន្មានឡើយ ។ | • **កត្តាខាងក្នុងខ្លួន :** ( មានចិត្តចង់ដោយខ្លួនឯង )<br>• មើលឃើញពី តម្រូវការ ឬផលប្រយោជន៍ចំពោះមុខ ) ។ |
| ការជ្រើសរើសប្រធានបទ | • គ្រូជាអ្នកកំណត់ | • កំណត់រួមគ្នាដោយផ្អែកលើតំរូវការ ឬបញ្ហាជាក់ស្តែងកំពុងជួបប្រទះ ។ |
| ការប្រើវិធីសាស្ត្រជាគោល | • គ្រូជាអ្នកផ្តល់ រីឯសិស្សជាអ្នកចាំតែទទួលព័ត៌មាន ។ | • ចូលរួមចែករំលែកនូវចំណេះដឹងនិងបទពិសោធន៍ដើម្បីបង្កើនសមត្ថភាព |

### ១.២. គោលការណ៍នៃការរៀនរបស់មនុស្សពេញវ័យ

មនុស្សចាស់ ឬមនុស្សពេញវ័យរៀនបានល្អប្រសើរបំផុតនៅពេលដែល :

- **គេមានបំណងផ្ទាល់ខ្លួន ( ចង់រៀនដោយខ្លួនឯង )**
  គេមានតម្រូវការដែលជាហេតុនាំឱ្យមានបំណងច្បាស់លាស់ផ្ទាល់ខ្លួនក្នុងការរៀន

- **គេមានតម្រូវការចំពោះមុខដើម្បីបំពេញ**

  នៅពេលដែលគេមើលឃើញថាការរៀននេះជួយឱ្យគេសំរេចបំណងរបស់គេ នោះរឹតតែធ្វើឱ្យគេកាន់តែមាន ឆន្ទៈក្នុងការរៀនកាន់តែខ្លាំង ឬខ្ពស់ថែមទៀត ។

- **ការរៀនមានលក្ខណៈចូលរួម**

  មនុស្សពេញវ័យ ជាទូទៅ ចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តក្នុងសកម្មភាពនៃការរៀន

- **ការរៀនផ្អែកលើបទពិសោធន៍**

  គេចូលចិត្តរៀនពីបទពិសោធន៍រវាងគ្នាទៅវិញទៅមក ឬអ្វីដែលទាក់ទងនឹងបទពិសោធន៍របស់ខ្លួន

- **ការរៀនមានលក្ខណៈឆ្លុះបញ្ចាំង**

  មនុស្សចាស់ ឬពេញវ័យចូលចិត្ត វិភាគ ឆ្លុះបញ្ចាំងលើទង្វើដែលបានធ្វើកន្លងមក រួចទាញយកមេរៀនសំរាប់ ការអនុវត្តន៍ឱ្យកាន់តែប្រសើរឡើងថែមទៀតទៅអនាគត ។

- **មានការផ្តល់មតិឆ្លើយតបឱ្យគ្នាទៅវិញទៅមក**

  ពួកគេរៀនមានប្រសិទ្ធភាពតាមរយៈការផ្តល់មតិឆ្លើយតបឱ្យគ្នាទៅវិញទៅមកបែបកែតម្រូវ និងគាំទ្រ ប៉ុន្តែ មិនបណ្តុះបង្អាប់ ។

- **មានការគោរពចំពោះគ្នាទៅវិញទៅមក**

  ការគោរព និងទុកចិត្តគ្នាទៅវិញទៅមករវាងគ្រូ និងសិស្ស គឺជាកត្តាជួយ ឬជំរុញឱ្យដំណើរការនៃការរៀន សូត្រប្រព្រឹត្តិទៅបានល្អ ។

- **មានបរិយាកាសសុវត្ថិភាព**

  បរិយាកាសដែលពោរពេញទៅដោយភាពសប្បាយរីករាយ ធូរស្រាលក្នុងអារម្មណ៍ ( មិនមានអារម្មណ៍ អៀនខ្មាសក្នុងការបញ្ចេញយោបល់ ឬធ្វើសកម្មភាពផ្សេងៗក្នុងការរៀន ) គឺជាបរិយាកាសដែលជួយ បង្ករលក្ខណៈ ឱ្យអ្នករៀនអាចរៀនបានដោយមានប្រសិទ្ធភាព ។

- **មានបរិយាកាសសុខស្រួល/ផាសុខ**

  ទីកន្លែងសមប្រកប មានផាសុខភាព ជួយសំរួលដល់រាងកាយ ឬការសម្រួលឥរិយាបទ គឺជាកត្តាជួយឱ្យអ្នករៀនទទួលបានភាពងាយស្រួលក្នុងការរៀន និងរៀនមានប្រសិទ្ធភាព ។

## ២, លក្ខណៈសម្បត្តិនៃគ្រូបណ្តុះបណ្តាល ឬអ្នកសំរបសំរួលដែលល្អ

| គុណភាព | អត្តចរិត និងអាកប្បកិរិយា | ជំនាញ/វិធីសាស្ត្រ |
| --- | --- | --- |
| • មានបទពិសោធន៍<br>• ចេះកំប្លុកកំប្លែង<br>• ទទួលខុសត្រូវ<br>• មានទំនុកចិត្ត<br>• រួសរាយរាក់ទាក់ហើយយល់ដឹងស៊ីជំរៅ ។<br>• បើកចិត្តទូលាយ<br>• មានថាមពល និងស្វាហាប់<br>• មិនវិនិច្ឆ័យទៅលើគំនិតអ្នកចូលរួម<br>• លើកទឹកចិត្ត<br>• ចេះបត់បែន | • មានទឹកមុខរីករាយ<br>• មានចិត្តអត់ធ្មត់<br>• ចេះអត់ឱន<br>• ព្យាយាមរៀនសូត្រ<br>• មានភាពស្និទ្ធស្នាល<br>• ផ្តល់ការគោរពដល់អ្នកដទៃ<br>• ជាអ្នកធ្វើគំរូល្អដល់អ្នកដទៃ | • ធ្វើឱ្យមានការចូលរួម<br>• ចេះសង្ខេប និងសំយោគគំនិតអ្នកចូលរួម<br>• ចេះរៀបចំចាត់ចែងដំណើរការ<br>• ចេះប្រាស្រ័យទាក់ទង<br>• ចេះស្តាប់<br>• ចេះសង្កេត<br>• ធ្វើការឡើងបង្ហាញ<br>• ចេះសួរ<br>• ចេះបង្កើត និងប្រើប្រាស់សំភារៈជំនួយ ។ |

## ៣, អ្វីដែលគ្រូបណ្តុះបណ្តាល ឬអ្នកសំរបសំរួលគួរធ្វើ

១. ធ្វើឱ្យអ្វីមានដំណើរការរលូន

២. ជួយសិក្ខាកាម ឱ្យអាចចែករំលែកគំនិត និងបទពិសោធន៍ (ឧទាហរណ៍ តាមរយៈការប្រើសំណួរ)

៣. ជួយឱ្យសិក្ខាកាមមានអារម្មណ៍ល្អ (ផ្តល់ការយកចិត្តទុកដាក់តាមរយៈខ្សែភ្នែក និងលើកទឹកចិត្ត)

៤. រក្សាការយកចិត្តទុកដាក់របស់សិក្ខាកាមឱ្យផ្តោតទៅលើប្រធានបទ និងដំណើរការបង្រៀន/ សំរបសំរួលកុំឱ្យចាកប្រធាន ។ មានវគ្គ មានឃ្លាច្បាស់លាស់ រវាងពីផ្នែកមួយទៅផ្នែកមួយទៀត ចៀសវាង

ការភាន់ច្រឡំ ពោលគឺឱ្យគាត់ដឹងពីស្ថានភាព និងការសំរេចចិត្ត ដែលបានពីការពិភាក្សា មុនពេលឈាន ចូលទៅប្រធានបទថ្មី ឬបន្ទាប់ទៀត ។

៥. ធ្វើឱ្យការពិភាក្សាប្រព្រឹត្តទៅដោយរលូន ឬសកម្ម ។ សង្ខេបអ្វីដែលពួកគាត់បាននិយាយ ជាពិសេស សង្ខេបគំនិតរបស់អ្នកនិយាយតិច ។ វិធីនេះគឺធ្វើឱ្យអ្នកអៀនខ្មាស់ ប្រាកដថាគេគ្រប់គ្នាបានឮ គំនិត នោះ ។ និងធ្វើឱ្យមានទំនាក់ទំនងពីគំនិតមួយទៅគំនិតមួយទៀត ។

៦. បង្ហាញការគិតគូរយកចិត្តទុកដាក់ពីអារម្មណ៍របស់ក្រុមទាំងមូល ។ ស្វែងយល់ថាតើ អារម្មណ៍ពួកគាត់ នៅជាមួយគ្នាឬទេ ឬធុញទ្រាន់ ឬហត់នឿយ ឬខឹង ? ដើម្បីរកវិធីសាស្ត្របំបាត់ភាពធុញថប់នេះ ។

៧. មុននឹងឆ្លងពីសកម្មភាពមួយទៅសកម្មភាពមួយទៀត ឬពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ត្រូវធ្វើការសង្ខេបគំនិតដែលបានធ្វើការសំរេចរួមគ្នា ដើម្បីឱ្យក្រុមទាំងមូលបានដឹងថាពួកគេបានធ្វើ អ្វីខ្លះរួមគ្នាពីមុនមក ។

## ៤. ឧបករណ៍ និង វិធីសាស្ត្រមួយចំនួនសំរាប់ប្រើប្រាស់ក្នុងការសំរបសំរួល

### ១. ការបំផុសគំនិតក្នុងក្រុមធំ

| **អត្ថន័យ :** | **ជំហានឬសកម្មភាព** |
|---|---|
| គឺជាដំណើរការនៃការប្រមូលគំនិត ឬដំណោះស្រាយដែលអាចមាន ទៅនឹងបញ្ហាអ្វីមួយ ដែលក្នុងនោះ មិនតំរូវឱ្យគ្រប់គ្នាត្រូវតែឆ្លើយនេះទេ ។ | • អ្នកសំរបសំរួលសួរសំណួរ (ដោយផ្ទាល់មាត់ ឬសរសេរលើផ្ទាំងក្រដាសធំ) ។<br>• សិក្ខាកាមឬអ្នកចូលរួមផ្តល់ចំលើយម្តងម្នាក់ៗ (អ្នកណាមាន យោបល់ចង់និយាយមុនក៏បាន) ។<br>• អ្នកសំរបសំរួលកត់ត្រាចំលើយរបស់សិក្ខាកាមដាក់លើក្តារខៀន ឬផ្ទាំងក្រដាសធំ ។<br>• អ្នកសំរបសំរួលផ្តល់ឱកាសឱ្យអ្នកចូលរួមធ្វើការសួរបញ្ជាក់ទៅលើចំលើយដែលខ្លួនបានកត់ត្រាដើម្បីឱ្យដឹងថាវាមានលក្ខណៈច្បាស់លាស់ និងអាចយល់បានឬទេ បន្ទាប់ពីការបញ្ចេញគំនិត ត្រូវបានបញ្ចប់ ។<br>• អ្នកសំរបសំរួលបើកឱកាសឱ្យអ្នកចូលរួមពិភាក្សាទៅលើចំលើយចូលរួមទាំងអស់ដោយសង្ខេបខ្លី ដើម្បីឱ្យពួកគេទាញ |
| **គោលបំណង :** | |
| ដើម្បីប្រមូលគំនិត ឬជំរើសផ្សេងៗមួយចំនួនដែលទាក់ទងនឹងបញ្ហា ។ | |
| **សំភារៈដែលត្រូវការ :** | |
| • ប៊ិចហ្វឺតសំរាប់សរសេរ<br>• ក្តារខៀន ឬផ្ទាំងក្រដាសធំ | |

<table>
<tr><td></td><td>ចេញនូវសេចក្តីសន្និដ្ឋានមួយ ។<br>• (ជាជំរើស) ប្រសិនបើគេត្រូវធ្វើការសំរេចចិត្តអ្វីមួយដោយផ្អែកលើគំនិតទាំងនេះ នោះអ្នកសំរបសំរួលត្រូវបំផុសរកលក្ខណៈវិនិច្ឆ័យដើម្បីវាយតំលៃទៅលើចំលើយចូលរួមទាំងនោះម្តងមួយ មុននឹងឈានទៅធ្វើការសំរេចចិត្ត ។</td></tr>
<tr><td colspan="2">កំណត់ចំណាំ :<br>គ្មានការវិនិច្ឆ័យលើចំលើយរបស់អ្នកចូលរួមណាម្នាក់ថាខុស ឬត្រូវឡើយនៅក្នុងដំណាក់កាលនេះ បើមិនដូច្នោះទេ គោលបំណងនៃការប្រមូលគំនិតឬជំរើសផ្សេងៗទៅនឹងបញ្ហានឹងមិនបានសំរេច ឡើយ ។</td></tr>
</table>

## ២. ការងារជាដៃគូ

<table>
<tr><th>អត្ថន័យ :</th><th>ជំហានឬសកម្មភាព</th></tr>
<tr><td>គឺជាដំណើរការនៃការបំផុសគំនិតតាមរយៈការពិភាក្សាជាដៃគូ ពីរៗនាក់ទៅលើសំណួរ ឬប្រធានបទអ្វីមួយ ។</td><td rowspan="6">• អ្នកសំរបសំរួលសួរសំណួរ (ដោយផ្ទាល់មាត់ ឬសរសេរលើផ្ទាំងក្រដាសធំ) ។<br>• អ្នកសំរបសំរួលប្រមូលចំលើយទៅនឹងសំណួរ ឬប្រធានបទចេញពីដៃគូម្តងមួយៗរួចកត់ត្រាចំលើយរបស់សិក្ខាកាមដាក់លើក្តារខៀន ឬផ្ទាំងក្រដាសធំ ។<br>• អ្នកសំរបសំរួលផ្តល់ឱកាសឱ្យអ្នកចូលរួមធ្វើការសួរបញ្ជាក់ទៅលើចំលើយដែលខ្លួនបានកត់ត្រាដើម្បីឱ្យដឹងថាវាមានលក្ខណៈច្បាស់លាស់  និងអាចយល់បានឬទេ បន្ទាប់ពីការបញ្ចេញគំនិតត្រូវបានបញ្ចប់ ។<br>• អ្នកសំរបសំរួលបើកឱកាសឱ្យអ្នកចូលរួមពិភាក្សាទៅលើចំលើយចូលរួមទាំងអស់ដោយសង្ខេបខ្លីដើម្បីឱ្យពួកគេទាញចេញនូវសេចក្តីសន្និដ្ឋានមួយ ។<br>• (ជាជំរើស) ប្រសិនបើគេត្រូវធ្វើការសំរេចចិត្តអ្វីមួយដោយផ្អែកលើគំនិតទាំងនេះ នោះអ្នកសំរបសំរួលត្រូវបំផុសគំនិតរកលក្ខណៈវិនិច្ឆ័យដើម្បីវាយតំលៃទៅលើចំលើយចូលរួមទាំងនោះម្តងមួយ មុននឹងឈានទៅធ្វើការសំរេចចិត្ត ។</td></tr>
<tr><th>គោលបំណង :</th></tr>
<tr><td>ដើម្បីប្រមូលគំនិត ឬជំរើសផ្សេងៗមួយចំនួនដែលទាក់ទងនឹងបញ្ហា ។</td></tr>
<tr><th>សំភារៈដែលត្រូវការ :</th></tr>
<tr><td>• ប៊ិចហ្វឺតសំរាប់សរសេរ<br>• ក្តារខៀន ឬផ្ទាំងក្រដាសធំ</td></tr>
</table>

**កំណត់ចំណាំ :**

*គ្មានការវិនិច្ឆ័យលើចំលើយរបស់អ្នកចូលរួមណាម្នាក់ថាខុស ឬត្រូវឡើយនៅក្នុងដំណាក់កាលនេះបើមិនដូច្នោះទេ គោលបំណងនៃការប្រមូលគំនិតឬជំរើសផ្សេងៗទៅនឹងបញ្ហា នឹងមិនបានសំរេចឡើយ ។*

## ៣. ការជជែករអ៊ូៗក្នុងក្រុមតូចដែលមានគ្នា បីៗ នាក់

| **អត្ថន័យ :** | **ជំហានឬសកម្មភាព** |
|---|---|
| គឺជាដំណើរការនៃការប្រមូលគំនិត ឬដំណោះស្រាយដែលអាចមានទៅនឹងបញ្ហាអ្វីមួយតាមរយៈនៃការជជែកគ្នាជាមួយអ្នកដែលអង្គុយនៅជិតឬជាប់គ្នាចំនួន ៣ៗ នាក់ ដោយមិនបាច់ងើបដើរទៅណាឡើយ ។<br>**គោលបំណង :**<br>ដើម្បីប្រមូលគំនិត ឬជំរើសផ្សេងៗមួយចំនួនដែលទាក់ទងនឹងបញ្ហា ។<br>**សំភារៈដែលត្រូវការ :**<br>• ក្រដាសកាតពណ៌សំរាប់ក្រុមនីមួយៗសរសេរគំនិតយោបល់របស់ខ្លួន ។<br>• ប៊ិចហ្វឺតសំរាប់សរសេរលើក្តាខៀន ឬផ្ទាំងក្រដាសធំ | • អ្នកសំរបសំរួលសួរសំណួរ (ដោយផ្ទាល់មាត់ ឬសរសេរលើផ្ទាំងក្រដាសធំ) ។<br>• អ្នកសំរបសំរួលឱ្យសិក្ខាកាមបែរមុខចូលគ្នាជាក្រុម ៣ ៗ នាក់ ។<br>• សិក្ខាកាមពិភាក្សាគ្នា ហើយកត់ត្រាចំលើយដាក់លើក្រដាសកាត ។<br>• អ្នកសំរបសំរួលប្រមូលចំលើយរបស់សិក្ខាកាម ឬឱ្យក្រុមនីមួយៗឡើងបិទលើក្តារខៀនឬផ្ទាំងក្រដាសធំដោយខ្លួនឯងក៏បាន ។<br>• អ្នកសំរបសំរួលផ្តល់ឱកាសឱ្យមានការសួរបញ្ជាក់ឬ បំភ្លឺប្រសិនបើមានចំណុចណាមួយមិនច្បាស់លាស់ក្នុងការយល់ ។<br>• អ្នកសំរបសំរួលធ្វើការបូកសរុបលទ្ធផលពិភាក្សារបស់សិក្ខាកាមដោយចាត់ចំលើយនៅលើក្រដាសកាតទាំងនោះជាក្រុមទៅតាមខ្លឹមសាររួមដែលគំនិតទាំងនោះបានបង្ហាញ ។<br>• (ជាជំរើស) អ្នកសំរបសំរួលអាចទាញចេញនូវសេចក្តីសន្និដ្ឋានមួយចេញពីបណ្តុំគំនិតទាំងនោះ ឬផ្សារភ្ជាប់គំនិតទាំងនោះទៅនឹងខ្លឹមសារ ឬប្រធានបទដែលខ្លួនចង់បង្ហាញ ។ |

**កំណត់ចំណាំ :**

*ការជជែករអ៊ូៗក្នុងក្រុមតូចដែលមានគ្នា ៣ៗនាក់នេះ ត្រូវធ្វើក្នុងរយៈពេលខ្លី ពោលគឺប្រមាណពី ៥ ទៅ ១០ នាទីប៉ុណ្ណោះ បើមិនដូច្នោះទេ វានឹងក្លាយទៅជាការពិភាក្សាក្នុងក្រុមតូចដូចធម្មតាដែរ ។*

## ៤. ការបំផុសគំនិតម្តងម្នាក់ៗក្នុងក្រុមធំ

<table>
<tr><th>អត្ថន័យ :</th><th>ជំហានឬសកម្មភាព</th></tr>
<tr><td>គឺជាដំណើរការនៃការប្រមូលគំនិតឬ ដំណោះស្រាយ ដែលអាចមានទៅនឹង បញ្ហាអ្វីមួយដែលក្នុងនោះតំរូវឱ្យសិក្ខាកាមឆ្លើយម្តងម្នាក់ៗតាមលេខរៀង ។</td><td rowspan="5"><ul><li>អ្នកសំរបសំរួលសួរសំណួរ (ដោយផ្ទាល់មាត់ ឬសរសេរលើផ្ទាំងក្រដាសធំ) ។</li><li>សិក្ខាកាមឬអ្នកចូលរួមផ្តល់ចំលើយម្តងម្នាក់ៗ  តាមលំដាប់លេខរៀងដែលកំណត់ដោយអ្នកសំរបសំរួល ។ អ្នកដែលគ្មានចំលើយត្រូវបានរំលងចោលមួយរយៈពេលសិន</li><li>អ្នកសំរបសំរួលកត់ត្រាចំលើយរបស់សិក្ខាកាមដាក់លើក្តារខៀន ឬផ្ទាំងក្រដាសធំ ។</li><li>អ្នកសំរបសំរួលត្រឡប់ទៅសួរអ្នកដែលខ្លួនបានរំលងលេខរៀងនោះវិញបន្ទាប់ពីដល់ជុំ (អ្នកចុងក្រោយគេបានឆ្លើយរួច) ប្រសិនបើមានពេល ។</li><li>អ្នកសំរបសំរួលផ្តល់ឱកាសឱ្យអ្នកចូលរួមធ្វើការសួរបញ្ជាក់ទៅលើចំលើយដែលខ្លួនបានកត់ត្រា ដើម្បីឱ្យដឹងថា វាមានលក្ខណៈច្បាស់លាស់ និងអាចយល់បានឬទេ បន្ទាប់ពីការបញ្ចេញគំនិត ត្រូវបានបញ្ចប់ ។</li><li>អ្នកសំរបសំរួលបើកឱកាសឱ្យអ្នកចូលរួមពិភាក្សាទៅលើចំលើយចូលរួមទាំងអស់ដោយសង្ខេបខ្លី ដើម្បីឱ្យពួកគេទាញចេញនូវសេចក្តីសន្និដ្ឋានមួយ ។</li><li>(ជាជំរើស) ប្រសិនបើគេត្រូវធ្វើការសំរេចចិត្តអ្វីមួយដោយផ្អែកលើគំនិតទាំងនេះ នោះអ្នកសំរបសំរួលត្រូវបំផុសរកលក្ខណៈវិនិច្ឆ័យដើម្បីវាយតំលៃទៅលើចំលើយចូលរួមទាំងនោះម្តងមួយ មុននឹងឈានទៅធ្វើការសំរេចចិត្ត ។</li></ul></td></tr>
<tr><th>គោលបំណង :</th></tr>
<tr><td>ដើម្បីប្រមូលគំនិត ឬជំរើសផ្សេងៗ មួយចំនួនដែលទាក់ទងនឹងបញ្ហា ។</td></tr>
<tr><th>សំភារៈដែលត្រូវការ :</th></tr>
<tr><td><ul><li>ប៊ិចហ្វឺតសំរាប់សរសេរ</li><li>ក្តាខៀន ឬផ្ទាំងក្រដាសធំ</li></ul></td></tr>
<tr><td colspan="2"><u>កំណត់ចំណាំ :</u><br>គ្មានការវិនិច្ឆ័យលើចំលើយរបស់អ្នកចូលរួមណាម្នាក់ថាខុស ឬត្រូវ ឡើយនៅក្នុងដំណាក់កាលនេះ បើមិនដូច្នោះទេ គោលបំណង នៃការប្រមូលគំនិតឬជំរើសផ្សេងៗ ទៅនឹងបញ្ហា នឹងមិនបានសំរេចឡើយ ។</td></tr>
</table>

## ៥. ការពិភាក្សាក្នុងក្រុមតូច

<table>
<tr><th>អត្ថន័យ :</th><th>ជំហានឬសកម្មភាព</th></tr>
<tr><td>គឺជាការជជែកវែកញែកផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកទៅលើប្រធានបទ ឬបញ្ហាអ្វីមួយ ។</td><td rowspan="5">• អ្នកសំរបសំរួលបង្ហាញពីប្រធានបទ ឬបញ្ហា ឬកិច្ចការដែលត្រូវពិភាក្សា ។<br>• អ្នកសំរបសំរួលផ្តល់ការណែនាំលំអិតអំពីរបៀបធ្វើកិច្ចការនោះដែលរួមមាន :<br>↳ សំណួរឬកិច្ចការដែលត្រូវពិភាក្សា<br>↳ រយៈពេលដែលផ្តល់ឱ្យសំរាប់ការពិភាក្សា<br>↳ ទំរង់នៃការបង្ហាញលទ្ធផលពិភាក្សាទៅក្រុមធំ<br>• អ្នកសំរបសំរួលបែកចែកសិក្ខាកាមទៅតាមក្រុម<br>• សិក្ខាកាមធ្វើការពិភាក្សាតាមក្រុមតូចរៀងខ្លួន<br>• សិក្ខាកាមបង្ហាញលទ្ធផលពិភាក្សារបស់ក្រុមខ្លួនទៅទំរង់ដែលអ្នកសំរបសំរួលបានណែនាំ ។<br>• អ្នកសំរបសំរួលបើកឱកាសឱ្យសិក្ខាកាមក្រុមដទៃទៀតធ្វើការសួរបញ្ជាក់ ។<br>• អ្នកសំរបសំរួលធ្វើការសង្ខេបលទ្ធផលរួមនៃការពិភាក្សារបស់ក្រុមនីមួយៗហើយទាញចេញនូវសេក្តីសន្និដ្ឋានរួមមួយ ឬឱ្យក្រុមសិក្ខាកាមជាអ្នកធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯងក៏បាន ។</td></tr>
<tr><th>គោលបំណង :</th></tr>
<tr><td>ដើម្បីផ្លាស់ប្តូរបទពិសោធន៏ និងរៀនសូត្រពីគ្នាទៅវិញទៅមក ។</td></tr>
<tr><th>កំណត់សំគាល់ :</th></tr>
<tr><td>• ក្រដាសផ្ទាំងធំ ឬក្រដាសកាត ពណ៌ផ្សេងៗ ។<br>• ប៊ិចហ្វឺតពណ៌ខៀវ ឬខ្មៅសំរាប់សរសេរ</td></tr>
<tr><td colspan="2"><u>កំណត់ចំណាំ :</u><br>• សំណួរ ឬកិច្ចការដែលឱ្យសិក្ខាកាមពិភាក្សាត្រូវមានលក្ខណៈច្បាស់លាស់ងាយយល់ ហើយសមស្របទៅនឹង ពេលវេលាដែលផ្តល់ឱ្យសំរាប់ធ្វើការពិភាក្សា ។<br>• មធ្យោបាយនៃការចែកក្រុមនិងទំរង់នៃការបង្ហាញលទ្ធផលពិភាក្សាទៅក្រុមធំមានច្រើនយ៉ាងសំរាប់អ្នកសំ របសំរួលជ្រើសរើស ។<br>• ក្រុមពិភាក្សាមិនគួរមានគ្នាលើសពី ៦ ឬ៧ នាក់ឡើយ ។</td></tr>
</table>

## ៦. ករណីសិក្សា

<table>
<tr><th>អត្ថន័យ ៖</th><th>ជំហានឬសកម្មភាព</th></tr>
<tr><td>វាជាការជជែកពិភាក្សាគ្នាអំពីខ្លឹមសារនៃសាច់រឿងអ្វីមួយ ដែលជាទូទៅគេតំរូវឱ្យអ្នកពិភាក្សាឆ្លើយទៅនឹងសំណួរដែលមានភ្ជាប់នៅចុងបញ្ចប់នៃសាច់រឿងនោះ ។</td><td rowspan="5">• អ្នកសំរបសំរួលពន្យល់ប្រាប់ទៅក្រុមធំទាំងមូលអំពីនីតិវិធីនៃការធ្វើការពិភាក្សាទៅលើករណីសិក្សា ដែលក្នុងនោះរួមមាន ៖<br>➢ អ្វីជាប្រធានបទ ឬសាច់រឿងដែលត្រូវពិភាក្សា<br>➢ តើត្រូវបែងចែកសិក្ខាកាមជាប៉ុន្មានក្រុម ?<br>➢ តើក្រុមនីមួយៗនឹងពិភាក្សាករណីសិក្សាតែមួយដូចគ្នា ឬខុសគ្នា ?<br>➢ តើពួកគេមានពេលប៉ុន្មាននាទីសំរាប់ធ្វើការពិភាក្សា ?<br>➢ តើពួកគេនឹងត្រូវបង្ហាញលទ្ធផលនៃការពិភាក្សាលើករណីសិក្សានោះតាមរបៀបដូចម្តេច ?<br>• អ្នកសំរបសំរួលផ្តល់ឱកាសឱ្យសិក្ខាកាមសួរបញ្ជាក់ទៅលើការណែនាំរបស់ខ្លួនដើម្បីបញ្ជាក់ការយល់ដឹងរបស់ពួកគេ ។<br>• អ្នកសំរបសំរួលធ្វើការបែងចែកសិក្ខាកាមទៅតាមក្រុមនីមួយៗឱ្យធ្វើការពិភាក្សា លើករណីសិក្សា ។<br>• ក្រុមសិក្ខាកាមធ្វើការបង្ហាញលទ្ធផលពិភាក្សាទៅតាមទំរង់ដែលអ្នកសំរបសំរួលបានកំណត់ឱ្យ ។<br>• អ្នកសំរបសំរួលធ្វើការបូកសរុបលទ្ធផល ដោយធ្វើការសង្ខេប និងទាញចេញនូវសេចក្តីសន្និដ្ឋានរួមមួយ ។<br>• ជាជំរើស អ្នកសំរបសំរួលអាចធ្វើការពន្យល់បកស្រាយ និងទាញភ្ជាប់លទ្ធផលពិភាក្សារបស់សិក្ខាកាមទៅនឹងខ្លឹមសារ ឬទ្រឹស្តីអ្វីមួយដែលខ្លួនចង់បង្ហាញ ។</td></tr>
<tr><th>គោលបំណង ៖</th></tr>
<tr><td>ដើម្បីផ្តល់ជាឧទាហរណ៍អំពីស្ថានភាពអ្វីមួយសំរាប់ឱ្យអ្នកពិភាក្សាធ្វើការសិក្សាស្វែងយល់ ឆ្លុះបញ្ចាំង និងដកបទពិសោធន៍ ។</td></tr>
<tr><th>សំភារៈដែលត្រូវការ ៖</th></tr>
<tr><td>• ឯកសារអំពីករណីសិក្សាសំរាប់ចែកគ្រប់សិក្ខាកាម ។<br>• ក្រដាសផ្ទាំងធំ ឬក្រដាសកាតពណ៌ផ្សេងៗគ្នាមួយចំនួនទៅតាមការណែនាំរបស់អ្នកសំរបសំរួល ។<br>• ប៊ិចហ្វឺតពណ៌ខៀវ ឬខ្មៅសំរាប់សរសេរ ។</td></tr>
<tr><td colspan="2"><u>កំណត់ចំណាំ ៖</u><br>• ជាទូទៅ គឺច្រើនជារឿងពិត ជាក់ស្តែងអំពីស្ថានភាពអ្វីមួយជាជាងការច្នៃប្រឌិត ។<br>• ត្រូវមានលក្ខណៈខ្លីល្មមហើយមានន័យសមស្របទៅនឹងគោលបំណងនៃការឆ្លុះបញ្ចាំង<br>• ជាជំរើស ជួនកាលគេអាចឱ្យក្រុមនីមួយៗពិភាក្សាករណីសិក្សាខុសៗគ្នាក៏បាន ។</td></tr>
</table>

## ៧. ការសំដែងតួ

<table>
<tr><th>អត្ថន័យ :</th><th>ជំហានឬសកម្មភាព</th></tr>
<tr><td>គឺជាការសំដែងឈុតឆាកនៃស្ថានភាពអ្វីមួយដោយមនុស្សមួយក្រុម</td><td rowspan="5">• អ្នកសំរបសំរួល ប្រកាសប្រាប់ក្រុមធំទាំងមូលអំពីការសំដែងតួដែលក្នុងនោះរួមមាន :<br>➷ តើអ្នកសំដែងតួនឹងសំដែងអំពីអ្វី ?<br>➷ អ្វីខ្លះដែលអ្នកទស្សនា ក៏ដូចជា អ្នកសង្កេតការណ៏ (ប្រសិនបើមាន) ត្រូវធ្វើការសង្កេត ?<br>➷ មានកិច្ចការអ្វីខ្លះដែលទាំងអស់គ្នាត្រូវធ្វើបន្ទាប់ពីការសំដែងចប់ ?<br><br>• ក្រុមសំដែងតួធ្វើការសំដែង អ្នកទស្សនា និងអ្នកសង្កេតការណ៏ ធ្វើការសង្កេត ។<br>• អ្នកសំរបសំរួល ដឹកនាំក្រុមសិក្ខាកាមធ្វើការឆ្លុះបញ្ចាំង ដោយប្រើបញ្ជីរសំណួរដែលខ្លួនបានព្រៀងទុកនៅលើក្រដាសកាត ឬ ផ្ទាំងក្រដាសធំ ។<br>• សិក្ខាកាមឆ្លើយសំណួរឆ្លុះបញ្ចាំង របស់អ្នកសំរបសំរួល<br>• អ្នកសំរបសំរួលធ្វើការបូកសរុបចំលើយរបស់សិក្ខាកាម ដោយធ្វើការសង្ខេប និងទាញចេញនូវសេចក្តីសន្និដ្ឋានមួយ ។<br>• អ្នកសំរបសំរួល ធ្វើការពន្យល់ និងទាញភ្ជាប់ចំណុចឆ្លុះបញ្ចាំងដែលសិក្ខាកាមបានលើកឡើង ទៅនឹងខ្លឹមសារទ្រឹស្តីដែលខ្លួនចង់បង្ហាញទាក់ទងនឹងសាច់រឿង ។</td></tr>
<tr><th>គោលបំណង :</th></tr>
<tr><td>ដើម្បីធ្វើបង្ហាញពីស្ថានភាពជាក់លាក់ណាមួយ ហើយទាញចេញនូវការឆ្លុះបញ្ចាំង ។</td></tr>
<tr><th>សំភារៈដែលត្រូវការ :</th></tr>
<tr><td>• ទីកន្លែងធំល្មមអាចធ្វើការសំដែងបាន ។<br>• គេអាចកែច្នៃរបស់របរដែលមានស្រាប់នៅជុំវិញខ្លួនដើម្បីធ្វើជាសំភារៈតុបតែងខ្លួន និងប្រើប្រាស់ក្នុងការសំដែង ។</td></tr>
<tr><td colspan="2"><u>កំណត់ចំណាំ :</u><br>• មានលក្ខណៈខ្លីល្មម ហើយចៀសវាងការសំដែង ដោយបំផ្លើស ឬលេងសើចច្រើនហួសពីការពិត ។<br>• ប្រសិនបើចាំបាច់ អ្នកសំរបសំរួលអាចចែកក្រដាសដែលពណ៌នាអំពីឈុតឆាកសាច់រឿង និងពាក្យពេចន៏ដែលតួសំដែងត្រូវនិយាយ ទៅឱ្យក្រុមសិក្ខាកាមដែលត្រូវឡើងសំដែងនោះមើលជាមុន ។<br>• ជាការល្អ អ្នកសំរបសំរួលត្រូវ ត្រៀមសំណួរឆ្លុះបញ្ចាំងអំពីការសំដែងតួទុកជាមុន ។</td></tr>
</table>

## ៨, ការពិភាក្សាបែបវេទិកាតុកាហ្វេឬកាហ្វេអភិវឌ្ឍន៍

| **អត្ថន័យ :** | **ជំហានឬសកម្មភាព** |
|---|---|
| គឺជាទំរង់នៃការជជែកពិភាក្សាគ្នានៅក្នុងក្រុមតូច បែបលក្ខណៈសាមញ្ញដែលនៅទីបញ្ចប់មិនតំរូវឱ្យ មានការសំរេចចិត្តអ្វីមួយឡើយ<br><br>**គោលបំណង :**<br>ដើម្បីផ្លាស់ប្តូមតិយោបល់ និងចែករំលែកបទពិសោធន៏ រវាងគ្នាទៅវិញទៅមក ។<br><br>**សំភារៈដែលត្រូវការ :**<br>☞ ផ្ទាំងក្រដាសធំ<br>☞ ប៊ិចហ្វឺតពណ៌ខៀវ និងខ្មៅ | • អ្នកសំរបសំរួលបិទបង្ហាញប្រធានបទសំរាប់ការពិភាក្សានៅលើផ្ទាំងក្រដាសធំមួយ ។<br>• អ្នកសំរបសំរួលប្រាប់អំពីដំណើរការជាជំហាន១ៗនៃការពិភាក្សានិងរយៈពេលដែលផ្តល់ឱ្យនៅក្នុងជំហាននីមួយៗ ។<br>↳ **ជុំទី ១ :** ពិភាក្សាតាមក្រុមរៀងខ្លួន<br>↳ **ជុំទី ២ :** ក្រុមនីមួយៗជ្រើសរើសសមាជិកម្នាក់សំរាប់ធ្វើជាម្ចាស់ផ្ទះប្រចាំក្រុមរបស់ខ្លួន អ្នកដទៃទៀតក្រៅពីនេះត្រូវធ្វើជាភ្ញៀវទៅចូលរួមស្តាប់លទ្ធផលនិងពិភាក្សាជាមួយក្រុមផ្សេងៗទៀត ។<br>• អ្នកសំរបសំរួលផ្តល់ឱកាសឱ្យមានការសួរបញ្ជាក់ឬបំភ្លឺ<br>• អ្នកសំរបសំរួលបែងចែកសិក្ខាកាមទៅតាមក្រុមតូច<br>• ក្រុមសិក្ខាកាមធ្វើការពិភាក្សានៅក្នុងជុំទី ១<br>• ក្រុមសិក្ខាកាមធ្វើការពិភាក្សានៅក្នុងជុំទី ២<br>• អ្នកសំរបសំរួលអាចសួរបញ្ជាក់អំពីចំណាប់អារម្មណ៏ទូទៅរបស់អ្នកចូលរួមទៅលើលទ្ធផលនៃការពិភាក្សារបស់គ្រប់ក្រុមទាំងអស់ ។ |

***កំណត់ចំណាំ :***

- *ការកត់ត្រាលទ្ធផលពិភាក្សារបស់ក្រុមនីមួយៗ និងការតំរូវឱ្យគ្រប់គ្នាបានចូលរួមគ្រប់ក្រុមពិភាក្សាដទៃទៀត គឺជាជំរើស ។*
- *វាអាចជាមធ្យោបាយល្អមួយសំរាប់ការស្វែងយល់នូវទស្សនៈរបស់មនុស្សក្នុងវ័យ ឬជំនាន់ខុសគ្នា ឬ ទស្សនៈរបស់បុរស និងស្ត្រី ទៅលើប្រធានបទតែមួយ ប្រសិនបើការបែងចែកក្រុមធ្វើឡើងទៅតាម គោលការណ៏នេះ ។*

## ៩.    ការធ្វើសំភាសន៍ជាមួយអ្នកជំនាញឬអ្នកមានបទពិសោធន៍

<table>
<tr><th>អត្ថន័យ :</th><th>ជំហានឬសកម្មភាព</th></tr>
<tr><td>គឺជាវេទិការនៃការសួរ ឆ្លើយរវាងអ្នកចូលរួម និងអ្នកជំនាញឯកទេស  ឬអ្នកដែលមានចំណេះដឹងនិង បទពិសោធន៍ច្រើនលើការងារជាក់លាក់អ្វីមួយ ។</td><td rowspan="5">
• អ្នកសំរបសំរួលប្រាប់អំពីប្រធានបទដែលអ្នកជំនាញ ឬអ្នកមានបទពិសោធន៍នោះនឹងនិយាយឱ្យសិក្ខាកាមបានដឹងជាមុន ដើម្បីឱ្យពួកគេត្រៀមសំណួរសំរាប់សួរ ។<br>
• ក្នុងការត្រៀមរៀបចំសំណួរ អ្នកសំរបសំរួលអាចឱ្យសិក្ខាកាមពិភាក្សាគ្នាជាក្រុមតូច ឬជាដៃគូពីរៗនាក់ក៏បាន ដោយឱ្យពួកគេសរសេរសំណួរទាំងនោះដាក់លើក្រដាសកាត ។ គេអាចត្រៀមសំណួរច្រើន ប៉ុន្តែមិនប្រាកដថា គេនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការសួរសំណួរទាំងអស់នោះទេ ។<br>
• អ្នកសំរបសំរួលផ្តល់ការណែនាំអំពីនីតិវិធីក្នុងការសួរទៅដល់ក្រុមសិក្ខាកាមនៅមុនពេលចាប់ផ្តើមដំណើរការនៃការសំភាសន៍ ដែលរួមមានដូចខាងក្រោម :<br>
➷ ក្នុង ១ ក្រុមឬដៃគូនីមួយៗសួរបានតែពីសំណួរប៉ុណ្ណោះក្នុង មួយលើក ដើម្បីទុកពេលឱ្យក្រុម ឬដៃគូដទៃទៀតបានសួរគ្រប់គ្នា  ។ បន្ទាប់ពីសួរសំណួរនីមួយៗរបស់ខ្លួនរួចគេ ត្រូវហុចក្រ ដាសកាតសំណួរនោះ ទៅឱ្យអ្នកសំរបសំរួលបិទលើ ក្តារខៀន ។<br>
➷ ហាមសួរសំណួរដែលមានក្រុម ឬដៃគូដទៃបានសួររួចហើយ ។<br>
➷ ត្រូវមានអ្នកកត់ត្រាម្នាក់ ( អាចជាអ្នកសំរបសំរួលខ្លួនឯងផ្ទាល់ ឬសិក្ខាកាមដែល ស្ម័គ្រចិត្ត) ឡើងមកអង្គុយក្បែរ អ្នកជំនាញដើម្បីចាំកត់ត្រាចំលើយ ។<br>
➷ ត្រូវមានម្នាក់ទៀត ( អាចជាសមាជិកក្រុមអ្នកសំរបសំរួល ឬអ្នកស្ម័គ្រចិត្ត) នៅឈរចាំទទួលយកក្រដាសកាតពី អ្នកកត់ត្រាយកទៅបិទនៅលើក្តារខៀន ពោលគឺបិទនៅជិតឬជុំវិញក្រដាសកាតសំណួររបស់ចំលើយនោះ ។
</td></tr>
<tr><th>គោលបំណង :</th></tr>
<tr><td>ដើម្បីផ្តល់ឱកាសឱ្យអ្នកចូលរួមរៀនសូត្របទពិសោធន៍ ពីអ្នកជំនាញ ឬ អ្នកដែលមានបទពិសោធន៍នោះ ។</td></tr>
<tr><th>សំភារៈដែលត្រូវការ :</th></tr>
<tr><td>☞ កៅអី ឬពូកសំរាប់អង្គុយ<br>☞ ក្រដាសកាត និងហ្វឺតសំរាប់សរសេរ ។<br>☞ ម្ជុលឬស្កុតសំរាប់បិទកាត</td></tr>
</table>

| | |
|---|---|
| | ➢ បើនៅសល់ពេល អ្នកសំរបសំរួលអាចឱ្យក្រុម ឬដៃគូសិក្ខាកាមនីមួយៗសួរសំណួរដទៃទៀតរបស់ខ្លួនដែលនៅសល់ ។<br>• អ្នកសំរបសំរួលចាប់ផ្តើមដំណើរការនៃការសំភាសន៍<br>• អ្នកសំរបសំរួលថ្លែងអំណរគុណដល់បុគ្គល ឬក្រុមអ្នកជំនាញចំពោះការចែករំលែកបទពិសោធន៍របស់ពួកគេ ។<br>• អ្នកសំរបសំរួលឱ្យក្រុម ឬដៃគូសិក្ខាកាមនីមួយៗពិនិត្យមើលសំណួរចំលើយទាំងអស់របស់ខ្លួនឡើងវិញ ហើយធ្វើការពិចារណា ថាតើពួកគេបានរៀនសូត្រអ្វីខ្លះពីអ្នកជំនាញនោះឬទាំងនោះ និងថាតើពួកគេអាចនឹងយកអ្វីទៅអនុវត្តបានខ្លះនៅក្នុង ការងាររបស់ខ្លួន ។ |

***កំណត់ចំណាំ :***

- *ក្នុងការកត់ត្រា គេអាចកត់យកតែពាក្យគន្លឹះប៉ុណ្ណោះ ហើយគោរពទៅតាមគោលការណ៍នៃការប្រើកាតផង ។*
- *ការធ្វើសំភាសន៍ជាមួយអ្នកជំនាញ ឬអ្នកមានបទពិសោធន៍ មិនចាំបាច់តែត្រូវធ្វើជាមួយភ្ញៀវដែល មកពីខាងក្រៅនោះទេ គេអាចធ្វើជាមួយក្រុមសិក្ខាកាមដូចគ្នាក៏បានដែរ ដោយប្រើប្រាស់វិធីសាស្ត្រ នេះសំរាប់ឱ្យពួកគេផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ។*

## ១០. ការដើរជជែកគ្នា

| **អត្ថន័យ :** | **ជំហានឬសកម្មភាព** |
|---|---|
| គឺជាសកម្មភាពនៃការជជែកពិភាក្សាដោយការដើរបណ្តើរពិភាក្សាបណ្តើរទៅលើរឿងរ៉ាវ ឬប្រធានបទអ្វីមួយ ។<br>**គោលបំណង :**<br>ដើម្បីផ្តល់ឱកាសឱ្យអ្នកចូលរួមបានចែករំលែក និងរៀនសូត្រពីគ្នាទៅ | • អ្នកសំរបសំរួលត្រូវបំផុសគំនិតសិក្ខាកាមជាមុន អំពីប្រធានបទដែលគេចង់លើកឡើងសំរាប់ជជែកពិភាក្សា ដោយសរសេរកត់ត្រាទុកនូវចំណងជើងប្រធានបទទាំងនោះ និងបញ្ហាជាក់លាក់ណាមួយដែលពាក់ព័ន្ធនៅលើក្តារខៀន ឬក្រដាសកាត ។ ឧទាហរណ៍ ប្រធាននៃការពិភាក្សាគឺ ***(ការធ្វើផែនការជាមួយថ្នាក់ដឹកនាំសហគមន៍)*** បញ្ហាជាក់លាក់ដែលពាក់ព័ន្ធគឺ ***(ខ្វះការប្តេជ្ញាចិត្តក្នុងការអនុវត្តជាក់ស្តែង)*** ។ |

<table>
<tr><td>វិញទៅមក នូវបទពិសោធន៍ការងារអ្វីមួយ ។</td><td rowspan="3">
<ul>
<li>គេអាចអនុញ្ញាតឱ្យមានប្រធានបទក្នុងចន្លោះប្រហែលពី ៣ ទេ ៤ ប្រធានបទប៉ុណ្ណោះ ដោយអាស្រ័យទៅលើចំនួនសរុបទាំងអស់នៃសិក្ខាកាម ។</li>
<li>អ្នកសំរបសំរួល ឱ្យអ្នកចូលរួមដទៃទៀតជ្រើសរើសដាក់ឈ្មោះរបស់ខ្លួនទៅតាមប្រធានបទណាមួយដែលខ្លួនមានចំណាប់អារម្មណ៍ ។</li>
<li>អ្នកសំរបសំរួលកំណត់រយៈពេលសំរាប់ការដើរពិភាក្សា និងរយៈពេលសំរាប់ឱ្យក្រុមនីមួយៗត្រៀមរៀបចំសំរាប់ការបង្ហាញលទ្ធផលពិភាក្សារបស់ខ្លួនទៅកាន់ក្រុមធំ ។</li>
<li>សិក្ខាកាមចាប់ផ្តើមអនុវត្តន៍ ដំណើរការនៃការដើរជជែកគ្នា ។ នៅពេលដល់ម៉ោងកំណត់ ពួកគេត្រឡប់ចូលកន្លែងវិញ ហើយរៀបចំសំរាប់ការឡើងបង្ហាញ ។</li>
<li>សិក្ខាកាមតាមក្រុមនីមួយៗធ្វើការឡើងបង្ហាញលទ្ធផលពិភាក្សារបស់ខ្លួន ។</li>
</ul>
</td></tr>
<tr><td>សំភារៈដែលត្រូវការ :</td></tr>
<tr><td>☞ ផ្ទាំងក្រដាសធំ<br>☞ ប៊ិចហ្វឺតសំរាប់សរសេរ</td></tr>
<tr><td colspan="2"><u>កំណត់ចំណាំ :</u>
<ul>
<li>ជាការល្អគេច្រើនឱ្យសិក្ខាកាមអនុវត្ត ន៍ វិធីសាស្ត្រនេះនៅវេលាម៉ោង ២:០០ រសៀលដែលជាពេលចាប់ផ្តើមដំបូងនៃមេរៀនក្នុងពេលរសៀលដើម្បីកុំឱ្យសិក្ខាកាមមានការងងុយគេងក្រោយពីទទួលទានអាហារថ្ងៃត្រង់រួច ។</li>
<li>គេមិនចាំបាច់តំរូវឱ្យមានការកត់ត្រានៅក្នុងកំឡុងពេលនៃការដើរជជែកពិភាក្សាគ្នានោះទេ</li>
</ul>
</td></tr>
</table>

## ៥. ការធ្វើកិច្ចតែងការបង្រៀន ឬសំរបសំរួល

### ៥.១ និយមន័យ

តើអ្វីទៅជាកិច្ចតែងការបង្រៀន ឬសំរបសំរួល ហើយហេតុអ្វីបានជាចាំបាច់ត្រូវធ្វើវា ?

កិច្ចតែងការបង្រៀនគឺជាផែនការដែលរៀបរាប់ពីសកម្មភាពជាជំហានៗ ដែលអ្នកបង្រៀន ឬសំរបសំរួលត្រូវធ្វើជាមួយសិក្ខាកាម ដើម្បីឈានទៅសំរេចគោលបំណងនៃការរៀនសូត្រ ។ កិច្ចតែងការបង្រៀន ឬសំរបសំរួលដែលល្អគឺជាកិច្ចតែងការដែលបង្ហាញពី អ្វីដែលត្រូវធ្វើ ធ្វើនៅពេលណា ហើយធ្វើយ៉ាងដូចម្តេច ?។ អ្នកសំរបសំរួល ឬគ្រូបណ្តុះបណ្តាលត្រូវគិត និងសំរេចទៅលើចំណុច

ទាំងនេះជាមុន ដើម្បីធានាថាអ្វីៗគ្រប់ចំណុចសំខាន់ៗទាំងអស់នៃមេរៀនត្រូវបានដាក់បញ្ចូលទៅក្នុងមេរៀនដោយមិនមានការភ្លេចចន្លោះឡើយ ។ កិច្ចតែងការដែលល្អ គឺប្រាប់អ្នកសំរបសំរួល ឬគ្រូបណ្តុះបណ្តាលឱ្យដឹងជាមុនអំពីអ្វីដែលខ្លួនត្រូវធ្វើ ។ វាមានលក្ខណៈខុសគ្នារវាងគ្រូទាយ និងគ្រូបណ្តុះបណ្តាលនៅត្រង់ថា គ្រូទាយព្យាយាមប្រមើលមើលអ្វីដែលអាចទំនងជានឹងកើតមានឡើងក្នុងពេលអនាគត រីឯគ្រូបណ្តុះបណ្តាល គឺជាអ្នកព្យាយាមត្រួតត្រាឱ្យអ្វីៗមានដំណើរការប្រព្រឹត្តិទៅតាមផែនការដែលខ្លួនបានកំណត់នៅក្នុងកិច្ចតែងការរបស់ខ្លួន ក្នុងករណីតែណាជាក់ស្តែងណាមួយដែលខ្លួនអាចធ្វើទៅបាន ។

## ៥.២ សារៈសំខាន់នៃកិច្ចតែងការ

នៅពេលធ្វើកិច្ចតែងការ អ្នកសំរបសំរួល ឬគ្រូបណ្តុះបណ្តាលត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម ៖

**ក.** ជ្រើសរើសយកវិធីសាស្រ្តបង្រៀន ឬសំរបសំរួល សមស្រប ពោលគឺត្រូវឆ្លើយទៅនឹងសំណួរថា ៖ តើប្រធានបទនេះគួរត្រូវបង្រៀនយ៉ាងដូចម្តេច ?

**ខ.** កំណត់ពេលវេលាសមស្របក្នុងការអនុវត្តសកម្មភាពបង្រៀននីមួយៗ ពោលគឺឆ្លើយនឹងសំណួរថា ៖ តើសកមភាពនេះគួរត្រូវបង្រៀននៅពេលណា ហើយត្រូវប្រើរយៈពេលប៉ុន្មាន ?

**គ.** គិតពីចំនួនសិក្ខាកាម ឬអ្នកចូលរួម ពោលគឺឆ្លើយនឹងសំណួរថា ៖ តើមានសិក្ខាកាមសរុបទាំងអស់ចំនួនប៉ុន្មាននាក់ ?

**ឃ.** គិត និងសំរេចថាតើខ្លួនរំពឹងចង់សំរេចអ្វី ឬចង់ឱ្យសិក្ខាកាមចេះអ្វី នៅចុងបញ្ចប់នៃមេរៀនរបស់ខ្លួន ពោលគឺកំណត់គោលបំណងនៃមេរៀន ។

**ង.** សកម្មភាពជាជំហានៗ ដែលសិក្ខាកាម ឬអ្នកចូលរួមត្រូវធ្វើ ដើម្បីឈានទៅសំរេចគោលបំណងនៃមេរៀន ពោលគឺឆ្លើយទៅនឹងសំណួរថា ៖ តើដំបូងត្រូវធ្វើអ្វី បន្ទាប់មកធ្វើអ្វី និងជាបន្តបន្ទាប់រហូតដល់ចប់ ។

**ច.** ការប៉ាន់ប្រមាណលើសមត្ថភាពយល់ដឹងរបស់អ្នកចូលរួម ឬសិក្ខាកាម ពោលគឺឆ្លើយនឹងសំណួរថា ៖ តើធ្វើដូចម្តេចដើម្បីដឹងបានថា អ្នកចូលរួម ឬសិក្ខាកាមមានការយល់ដឹងបានប៉ុណ្ណា ?

## ៥.៣ ទំរង់ផ្សេងៗគ្នាមួយចំនួននៃកិច្ចតែងការបង្រៀន ឬសំរបសំរួល

❒ **គំរូទី ១**

**ឈ្មោះ ឬចំណងជើងនៃមេរៀន :** .................................................................

**ឈ្មោះអ្នកសំរបសំរួល :** **រយះពេល :** ......................

**គោលបំណងនៃមេរៀន :**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង :

- ..........................................................................................................
- ..........................................................................................................

**វិធីសាស្ត្រ :**

- ..........................................................................................................
- ..........................................................................................................

**សម្ភារៈដែលត្រូវការ :**

**ជំហាន/សកម្មភាព**

១. ...

២. ...

៣. ...

៤. ...

៥. ...

។ល។

❒ **គំរូទី ២**

| ចំណងជើងវគ្គ : | | | |
|---|---|---|---|
| ចំណងជើងមេរៀន : | | រយៈពេល : | |
| មេរៀនទី : | | ថ្ងៃទី : | |
| អ្នកសំរបសំរួល : | | | |

**គោលបំណងនៃមេរៀន :**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមទាំងអស់នឹង :

- ……………………………………………………………………………………………
- ……………………………………………………………………………………………

**ខ្លឹមសារសំខាន់ៗនៃមេរៀន :**

- ……………………………………………………………………………………………
- ……………………………………………………………………………………………
- ……………………………………………………………………………………………

| ល.រ. | សកម្មភាព / វិធីសាស្ត្រ | រយៈពេល និង សម្ភារៈ |
|---|---|---|
| ១. | | |
| ២. | | |
| ៣. | | |
| ៤. | | |
| ។ល។ | | |

❒ គំរូទី ៣

ចំណងជើងវគ្គ : ........................................................................................................................................................

មេរៀនទី : .......................... ចំណងជើងមេរៀន : ..............................................................................................................

| រយះពេល | គោលបំណងនៃមេរៀន | ខ្លឹមសារសំខាន់ៗ: | វិធីសាស្រ្ត/ដំណើរការ | សំភារៈ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៥.៤ របៀបសរសេរគោលបំណងនៃមេរៀន

វិធីសាស្ត្រមួយដើម្បីឆ្ពោះទៅរកការបង្កើតគោលបំណងគឺត្រូវបង្កើតតាមលក្ខណៈ (smart) ស្មាត មានន័យថា ជាក់លាក់ ហើយសាមញ្ញ អាចវាស់វែង អាចសំរេចបាន បង្ហាញនូវលទ្ធផលកំណត់បាននូវពេលវេលា។ ប្រសិនបើ គោលបំណងនៅក្នុងមេរៀនត្រូវបានកំណត់យ៉ាងល្អនោះ នឹងនាំឱ្យអ្នកសំរបសំរួលអាចនិយាយតាមលំហូរ ហើយអាចវាស់វែងភាពជោគជ័យ ក្នុងការសំរបសំរួលបានផងដែរ ។

**គោលបំណងត្រូវមានលក្ខណស្មាត ពោលគឺ :**

| | |
|---|---|
| Specific / Simple | ជាក់លាក់ ហើយសាមញ្ញ |
| Measurable | អាចវាស់វែងបាន |
| Achievable | អាចសំរេចទៅបាន |
| Realistic / Result oriented | មានលក្ខណៈប្រាកដប្រជា / ជាលទ្ធផល |
| Timely and/ Time bounded | មានរយៈពេលកំណត់ច្បាស់លាស់ |

ក្នុងការសរសេរគោលបំណង យើងត្រូវពិចារណាធាតុសំខាន់ ៣ ដូចខាងក្រោមៈ

១. **ពេលវេលា** : តើពេលណាអ្នកចង់ឃើញការផ្លាស់ប្តូរឥរិយាបទដែលចង់បាន?

២. **ការអនុវត្តការងារ** : តើអ្នករំពឹងទុកថាសិក្ខាកាមនឹងអាចធ្វើអ្វីដើម្បីអោយទទួលលទ្ធផលពីវគ្គបណ្តុះបណ្តាល ?

៣. **គុណភាព** : តើអ្នករំពឹងទុកថាសិក្ខាកាមអនុវត្តការងារបានល្អកំរិតណា?

**ឧទាហរណ៍ :**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាម នឹងអាចជ្រើសរើសយកវិធីសាស្ត្រនៃការសំរបសំរួលមួយចំនួនដែលខ្លួនមានទំុកចិត្តក្នុងការប្រើប្រាស់ ដើម្បីអនុវត្តក្នុងការសំរបសំរួលវគ្គរបស់ខ្លួននាពេលខាងមុខ ។

- **ពេលវេលា :** នៅចុងបញ្ចប់នៃមេរៀននេះ
- **ការអនុវត្តការងារ :** សិក្ខាកាមជ្រើសរើសយកវិធីសាស្ត្រសំរបសំរួលមួយចំនួនពីវគ្គនេះ ដើម្បី
- **គុណភាព :** ការអនុវត្តវិធីសាស្ត្រនៃការសំរបសំរួលដែលខ្លួនបានជ្រើសរើសប្រកបដោយទំនុកចិត្ត ។

## ៦. ការបង្កើត និងប្រើប្រាស់សម្ភារៈជំនួយ

### ៦.១. ប្រភេទផ្សេងៗគ្នានៃសម្ភារៈជំនួយ

អ្នកសំរបសំរួល/គ្រូបណ្តុះបណ្តាលដែលល្អ ត្រូវចេះកំណត់ បង្កើត ឬជ្រើសរើសយកសម្ភារៈជំនួយដែលសមស្របសំរាប់ប្រើប្រាស់ក្នុងការសំរបសំរួល ឬបណ្តុះបណ្តាលរបស់ខ្លួន ។ សូមពិចារណាប្រភេទផ្សេងៗគ្នានៃសម្ភារៈជំនួយមួយចំនួនដូចមានរៀបរាប់ខាងក្រោមនេះ ទៅតាមតម្រូវការនៃការប្រើប្រាស់របស់អ្នក ។

### ៦.២. ការប្រើប្រាស់ក្រដាសកាត

គេអាចប្រើប្រាស់កាតជាមធ្យោបាយក្នុងការបំផុស និងប្រមូលគំនិតទៅលើប្រធានបទ ឬបញ្ហាជាក់លាក់ណា មួយតាមរយៈនៃការសួរបំផុសគំនិត រួចទុកពេលឱ្យសិក្ខាកាមឆ្លើយដោយសរសេរដាក់លើក្រដាសកាតដែលបានចែកជូនទាំងនោះ ។

#### ៦.២.១ ទំហំ និងរៀងរូវរបស់កាត ៖

| | |
|---|---|
|  | កាតតូចសំរាប់ក្រុមតូច ប្រើសំរាប់សរសេរការពន្យល់បកស្រាយនូវគំនិត ផ្សេងៗជាពាក្យគន្លឹះ ឬប្រយោគខ្លីៗប៉ុណ្ណោះ ។ |
|  | កាតធំសំរាប់ក្រុមធំ ប្រើសំរាប់សរសេរការពន្យល់បកស្រាយនូវគំនិត ផ្សេងៗជាពាក្យគន្លឹះ ឬប្រយោគខ្លីៗ ។ |
|  | រាងពងក្រពើសំរាប់ប្រើជាចំណងជើងផ្សេងៗ |
|  | រាងមូលតូច ប្រើសំរាប់ដាក់លេខរៀងលំដាប់នៃជំហាន ឬដំណើរការនៃ ការធ្វើអ្វីមួយផ្សេងៗ ។ល។ ឧទាហរណ៍ ជំហាននៃការសំរេចចិត្ត ។ |

| | |
|---|---|
|  | រាងមូលមធ្យម ប្រើសំរាប់ដាក់ចំណងជើង ឬការរចនាពិសេសដើម្បីរំលេចនូវគំនិតណាមួយ ។ |
|  | រាងមូលធំ ប្រើសំរាប់បង្ហាញនូវចំណុចពិសេស ឬការរចនាពិសេសដើម្បីរំលេច ឬបញ្ជាក់គំនិតមួយចំនួន ។ |

### ៦,២,២ គោលការណ៍ក្នុងការសរសេរលើក្រដាសកាត :

- កាតមួយសន្លឹកសំរាប់គំនិតតែមួយប៉ុណ្ណោះ
- គេអាចសរសេរយ៉ាងច្រើនបំផុត ៣ បន្ទាត់នៅលើក្រដាសកាតមួយសន្លឹក
- ប្រើពាក្យគន្លឹះ
- សរសេរអក្សរធំៗល្មមអាចឱ្យគេអានបានពីចំងាយ
- គោរពតាមការកំណត់នៃការប្រើប្រាស់ពណ៌របស់ក្រដាស ប្រសិនបើមាន ឧទាហរណ៍ ក្រដាសពណ៌ខៀវសំរាប់សំណួរទី ១ ពណ៌លឿងសំរាប់សំណួរទី ២ ។ល។

## ៦,៣, ការប្រើប្រាស់ផ្ទាំងក្រដាសធំ ឬផ្ទាំងរូបភាព :

- សំរេច ឬកំណត់ថាតើត្រូវប្រើរូបភាពអ្វី ឬសរសេរអំពីអ្វី ដែលមានន័យសមស្របជាមួយនឹងសារ ដែលយើងចង់បង្ហាញ ។
- រូបភាព ឬអក្សរ មិនចាំបាច់ស្អាតក៏បាន តែគួរមានលក្ខណៈសាមញ្ញ អាចអានបាន ងាយយល់ មិនស្មុគ្រស្មាញពេកសំរាប់អ្នកអាន ឬអ្នកមើល ។
- ព្យាយាមប្រើពាក្យគន្លឹះ ឬប្រយោគខ្លីៗជាជាងប្រយោគវែងៗក្នុងការបកស្រាយគំនិតនៅលើផ្ទាំងក្រដាសធំ ។
- ករណីប្រើរូបភាព អាចមានពាក្យគន្លឹះខ្លះជាជំនួយក្នុងការពន្យល់រូបភាពក៏បាន ប្រសិនបើចាំបាច់ ។
- ដាក់លេខរៀងសំគាល់នៅលើផ្ទាំងក្រដាសធំ ឬរូបភាពដើម្បីឱ្យដឹងថា ផ្ទាំងក្រដាសធំមួយណា ឬ រូបណាត្រូវបង្ហាញមុន រូបណាបន្ទាប់ ចៀសវាងការភាន់ច្រឡំនៅចំពោះមុខអ្នកទស្សនា ។

## ៦.៤. ការប្រើប្រាស់របស់ពិត ឬសិម្បនិមិត្ត ៖

- សំរេច ឬកំណត់ថាតើត្រូវប្រើរបស់អ្វី
- គិតពីរបៀបប្រើវត្ថុ ឬរបស់នោះ
- ជាធម្មតា គេត្រូវលាក់ទុកវត្ថុ ឬរបស់ទាំងនោះសិន រហូតទាល់តែដល់ពេលដែលត្រូវប្រើវា ទើបគេយកវាចេញមកបង្ហាញ ។
- ត្រូវប្រាកដថា វត្ថុ ឬរបស់ដែលបង្ហាញនោះជារបស់ ឬវត្ថុដែលគ្រប់គ្នាអាចមើលឃើញច្បាស់
- និយាយទៅកាន់អ្នកទស្សនា ជាជាងនិយាយទៅកាន់វត្ថុដែលត្រូវបង្ហាញ

## ៦.៥. ការបញ្ចាំងស្លែដោយប្រើក្រដាសផ្លាស្ទីក និងមាស៊ីន LCD (Slide Projector/ PowerPoint) ៖

- រៀបចំផ្ទៃបញ្ចាំងឱ្យបានចំកណ្តាលនៃផ្ទៃផ្ទាំងក្រណាត់ស
- ត្រូវប្រាកដថា កញ្ចក់បញ្ចាំង មានសភាពស្អាត មិនប្រឡាក់ប្រឡូស
- ត្រូវសរសេរអក្សរ ឬដាក់រូបឱ្យមានទំហំធំល្មមដែលគេអាចមើលឃើញពីគ្រប់កន្លែងនៅក្នុងបន្ទប់ ។
- រៀបចំ Slides ដែលត្រូវបញ្ចាំងឱ្យមានលំដាប់លំដោយល្អ ( បង់លេខចំណាំបើចាំបាច់ )
- ដាក់ Slides បញ្ចាំងឱ្យត្រង់នៅលើផ្ទៃកញ្ចក់បញ្ចាំង ( ប្រសិនបើប្រើ Overhead Projector
- បិទម៉ាស៊ីនបញ្ចាំង នៅពេលបញ្ចាំងចប់ ឬក្នុងពេលដែលកំពុងនិយាយពីរឿងផ្សេងដែលមិនទាក់ ទងឹងប្រធានបទនៃការបញ្ចាំងទេនោះ ។
- និយាយទៅកាន់អ្នកស្តាប់

### វីដេអូ ៖

- ប្រើតែក្នុងករណីដែលវីដេអូនោះមានរូបភាពច្បាស់ ហើយធំល្មមអាចឱ្យគេមើលឃើញពីគ្រប់ទីកន្លែងនៅក្នុងបន្ទប់ ។
- ត្រូវប្រាកដថា កាសែតវីដេអូនីមួយៗដែលត្រូវប្រើ ត្រូវបានរៀបចំដាក់តាមលំដាប់លំដោយត្រឹមត្រូវ ( បង់លេខចំណាំបើចាំបាច់ ) ។
- ត្រូវមានចំណេះដឹងក្នុងការប្រើប្រាស់ប្រដាប់បញ្ជាពីចំងាយ និងទូរទស្សន៍ដែលត្រូវប្រើជាមួយវីដេអូនោះ ។

- បិទទូរទស្សន៍នៅពេលបញ្ចាំងចប់
- ឈុតឆាកដែលបញ្ចាំង ត្រូវមានលក្ខណៈសង្ខេបខ្លី មានន័យសមស្របតាមសារដែលយើងចង់ផ្តល់ឱ្យអ្នកអាន ។
- ទុកពេលបន្តិចឱ្យអ្នកទស្សនា សំរួលឥរិយាបទបន្ទាប់ពីទស្សនាចប់ មុនពេលចាប់ផ្តើមបន្តសាច់រឿងថ្មីទៀត ។
- ផ្តល់ការណែនាំច្បាស់លាស់ដល់អ្នកទស្សនា អំពីអ្វីដែលពួកគេត្រូវធ្វើ ទាក់ទងនឹងការទស្សនាវីដេអូនេះ ។
- ចៀសការនិយាយទៅកាន់អ្នកទស្សនាក្នុងពេលដែលខ្សែវីដេអូកំពុងតែបញ្ចាំង

## ៧. ការសន្ទនា និងការពិភាក្សា (Dialogue and Discussion)

**ការសន្ទនា( dialogue)**

មានប្រយោជន៍នៅពេលដែលយើងប្រើប្រាស់ការស្តាប់ដើម្បីស្វែងយល់ពីទស្សនៈរបស់អ្នកដទៃ និងដោយពុំមានការវិនិច្ឆ័យជាមុននូវអ្វីដែលគេកំពុងនិយាយក្នុងន័យដើម្បីការពារគំនិតខ្លួនឯង ។ ភាពខុសគ្នារវាងការសន្ទនា (dialogue)និងការពិភាក្សា (discussion) នៅត្រង់ថា ការសន្ទនា (dialogue) ច្រើនត្រូវបានគេធ្វើឡើងក្នុងន័យដើម្បីស្វែងយល់ជាទូទៅអំពីទស្សនៈនៃភាគីម្ខាងទៀត ដែលជាលទ្ធផលគឺភាគីទាំងពីរ មានការយល់ដឹងពីគ្នាច្រើនឡើង ឬប្រសើរឡើង ។ ចំណែកការពិភាក្សា (discussion) គឺមានទិសដៅ ឬបំណង ដើម្បីស្វែងយល់លំអិត ឬស៊ីជំរៅ និងជាចុងក្រោយ គឺនាំទៅរកការសន្និដ្ឋានរួមគ្នាមួយទៅលើប្រធានបទនៃការពិភាក្សា ។ ដោយយោងលើហេតុផលនេះ យើងឃើញថា ការសន្ទនា (dialogue) មានសារៈប្រយោជន៍ ឬផ្តល់ផ្លែផ្កាជាវិជ្ជមានច្រើនជាងការពិភាក្សា ក្នុងករណីដែលយើងមានបំណងចង់ស្វែងយល់ពីទស្សនៈរបស់ភាគីម្ខាងទៀត ក្នុងការស្វែងរកដំណោះស្រាយទៅនឹងបញ្ហាអ្វីមួយ ។

ខ្ញុំនិយាយក្នុងបំណងដើម្បីបង្ហាញ ឬសំដែងការពិត

និយាយ

ខ្ញុំនិយាយក្នុងបំណងដើម្បីធ្វើឱ្យភាគីម្ខាងទៀតផ្លាស់ប្តូរការយល់ឃើញរបស់គេ ។




ខ្ញុំស្តាប់ក្នុងបំណងដើម្បីរកចំណុចជំទាស់ ( បាទ/ចាស៎! ប៉ុន្តែ ,,, ) ។

ស្តាប់

ខ្ញុំស្តាប់ក្នុងបំណងដើម្បីស្វែងយល់ពីទស្សនៈរបស់ភាគីម្ខាងទៀត និងទទួលបានព័ត៌មានពីគេ ។

**<u>ដើម្បីធ្វើការសន្ទនាបានល្អ សមាជិកក្រុមគប្បី ឬត្រូវ :</u>**

☞ សួរសំណួរជាជាងនិយាយឃ្លាប្រយោគដែលបង្ហាញពីការវិនិច្ឆ័យរបស់ខ្លួន

☞ សួរសំណួរដើម្បីស្វែងយល់ពីគំនិតដែលគេមានក្នុងការគាំទ្រការយល់ឃើញរបស់គេជាជាងការប្រកែកតវ៉ាទៅលើខ្លឹមសារនៃប្រធានបទដែលគេនិយាយ ។

☞ ស្តាប់ដោយយកចិត្តទុកដាក់ និងដោយពុំធ្វើការផ្ទៀងផ្ទាត់អ្វីដែលគេនិយាយ ជាមួយនិងការប៉ាន់ស្មាន ឬសន្មត់ទុកជាមុនរបស់ខ្លួន ។

- ផ្នែកនៃការពិភាក្សាក៏ត្រូវបានគេហៅផងដែរថា ជាផ្នែកនៃការប្រាស្រ័យទាក់ទងបែបការពារខ្លួន (Defensive communication)

- ផ្នែកនៃការសន្ទនាក៏ត្រូវបានគេហៅផងដែរថា ជាផ្នែកនៃការប្រាស្រ័យទាក់ទងបែបសហការ (Co-operative communication)

- សារៈសំខាន់នៃផ្នែកអំពីការពិភាក្សា គឺនាំទៅរកការពង្រឹងសមត្ថភាពនៃការការពារខ្លួន (Capacity to defend oneself)

- សារៈសំខាន់នៃផ្នែកអំពីការសន្ទនា គឺនាំទៅរកការពង្រឹងសមត្ថភាពនៃការជួយគ្នាទៅវិញទៅមក (Capacity to support each other)

## ៨. ការការស្តាប់ប្រកបដោយភាពសកម្ម និងផ្តោតលើគោលបំណង

**Active and Purposeful Listening**

| | |
|---|---|
| **Active listening**<br>**ការស្តាប់សកម្ម** | ការស្តាប់មិនមែនជាសកម្មភាពបែបអសកម្មនោះទេ ។ អ្នកស្តាប់ មើលទៅហាក់ដូចជានៅស្ងៀមក្នុងពេលដែលអ្នកនិយាយកំពុងនិយាយ ប៉ុន្តែគេមិនមែនមានភាពអសកម្មនោះទេ ពោលគឺគេជាដៃគូយ៉ាងសកម្មនៅក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកនិយាយ ។ |
| **Focus of attention**<br>**ការផ្តោតអារម្មណ៍** | ពិតណាស់ថា មានពេលខ្លះអារម្មណ៍របស់អ្នកស្តាប់មិនបានស្ថិតនៅជាមួយអ្នកនិយាយទេ ។ ជាធម្មជាតិរបស់មនុស្ស ពេលខ្លះអ្នកស្តាប់ធ្វើការប្រៀបធៀបព័ត៌មានដែលខ្លួនបានទទួលពីអ្នកនិយាយ ជាមួយនិងអ្វីដែលខ្លួនធ្លាប់បានដឹង ឬធ្លាប់មានបទពិសោធន៍ ឬក៏ការសន្មត់ទុកជាមុននៅក្នុងចិត្តរបស់ខ្លួន ដែលការនេះ នាំឱ្យអ្នកស្តាប់បង្វែរការផ្តោតអារម្មណ៍ក្នុងការស្តាប់របស់ខ្លួនចេញពីអ្នកនិយាយអស់មួយរយៈពេល ។ |
| **Listening with a purpose**<br>**ស្តាប់ដោយមានគោលបំណង** | ជាទូទៅមនុស្សយើងស្តាប់ដោយមានគោលបំណងអ្វីមួយនៅក្នុងចិត្តដែលគោលបំណងនោះអាចមានលក្ខណៈជាវិជ្ជមាន ឬក៏អវិជ្ជមាន ។ គោលបំណងអវិជ្ជមាន គឺមានន័យសំដៅដល់ការស្តាប់ដែលមានគោលបំណងមើលស្រាលចំពោះអ្នកនិយាយ ឬស្វែងរកតែកំហុសរបស់អ្នកនិយាយ ។ ចំណែកគោលបំណងវិជ្ជមាន គឺមានន័យសំដៅដល់ការស្តាប់ដើម្បីប៉ាន់ប្រមាណរកភាពត្រឹមត្រូវ ដើម្បីចងចាំទុកនូវព័ត៌មាន ដើម្បីស្វែករកឱកាសក្នុងការជួយដោះស្រាយបញ្ហាផ្សេងៗរបស់អ្នកនិយាយ ដើម្បីរកគំនិតដែលខ្លួនអាចចូលរួម ឬផ្តល់ឱ្យ ឬដើម្បីស្វែងយល់ពីតម្រូវការពិតរបស់អ្នកនិយាយនៅពីក្រោយការនិយាយរបស់គាត់ ។ |

| | |
|---|---|
| **Reflective and Interpretive listening**<br>**ការស្តាប់ដោយឆ្លុះបញ្ចាំង និងស្វែងយល់ ពីអត្ថន័យ** | វាជាប្រការសំខាន់ណាស់ ប្រសិនបើយើងអាចញែកចេញបាន នូវភាពខុសគ្នារវាងអ្វីដែលគេនិយាយ ឬចង់មានន័យពិតប្រាកដ និងអ្វីដែលយើងធ្វើការសន្មត់អត្ថន័យទុកជាមុន ទៅលើអ្វីដែលគេនិយាយដោយខ្លួនឯង ។ យើងអាចសន្មត់អត្ថន័យខុសពី ន័យដែលគេចង់និយាយ ។ ញាណរបស់យើងអាចនឹងកំណត់អត្ថន័យ ហួសពីអ្វីដែលគេចង់ប្រាប់ ឬចង់បានន័យទាក់ទងនឹងពាក្យសំដីដែលគេ និយាយ ។ នេះគឺជាកំហុសឆ្គងដែលអ្នកស្តាប់គួរធ្វើការសួរបញ្ជាក់ជាមួយអ្នកនិយាយ ជាជាងសន្មត់តែខ្លួនឯង ។ |
| **Developmental listening**<br>**ការស្តាប់ប្រកបដោយការអភិវឌ្ឍន៍** | ការស្តាប់ប្រភេទនេះគឺមានន័យសំដៅដល់ការស្តាប់ក្នុងបំណងដើម្បីស្វែងរកឱកាសក្នុងការចូលរួមគំនិតបន្ថែម ឬការស្តាប់ដើម្បីស្វែងរកគន្លឹះ ឬសក្តានុពលក្នុងការជួយគាំទ្រដល់គំនិតអ្នកនិយាយ ។ |

## ៩. ប្រភេទនៃសំណួរ

គ្រូបណ្តុះបណ្តាល ឬអ្នកសំរបសំរួលដែលល្អ គឺត្រូវដឹងថា ពេលណាត្រូវសួរសំណួរអ្វី ។ តារាងខាងក្រោមនេះនឹងពន្យល់បន្ថែមអំពីអត្ថន័យនេះ ។

| ប្រភេទសំណួរ | ឧទាហរណ៍ | គោលបំណង |
|---|---|---|
| • **សំណួរបើក** | • តើអ្នកមានទស្សនៈដូចម្តេចចំពោះរឿងរ៉ាវអំពីការគ្រប់គ្រងគ្រោះមហន្តរាយនេះ ?<br>• តើអ្នកគិតថាស្ថានភាពនេះអាចនឹងកែលំអបានដោយរបៀបណា ?<br>• ហេតុដូចម្តេចបានជាវាកើតឡើងយ៉ាងដូច្នេះ ?<br>• ។ល។ | • ដើម្បីស្វែងយល់រឿងអ្វីមួយ<br>• ដើមម្បីយល់ដឹងពីស្ថានភាពរួមនៃសាច់រឿងអ្វីមួយ ។ |
| • **សំណួរបិទ** | • តើជំហានទាំងនេះមានលក្ខណៈសមហេតុផលដែរឬទេ ?<br>• តើអ្នកយល់ស្របទេថា ស្ថានភាពនេះនឹងនៅតែ | • ដើម្បីវាស់ស្ទង់លើការយល់ដឹង<br>• ដើម្បីទទួលបាននូវការបញ្ជាក់បន្ថែម ឬគាំទ្រនូវគំនិតរបស់ |

| | | |
|---|---|---|
| | បន្តកើតមាន ?<br>• តើមានអ្វីដែលទាក់ទងទៅនឹងការងាររបស់អ្នកផងដែរឬទេ ?<br>• ។ល។ | អ្នកសួរ ។ |
| • **សំណួរឆ្លុះបញ្ចាំង** | • តេមីលទៅអ្នកហាក់ដូចជាចង់និយាយថាពួកគេកំពុងមិនសប្បាយចិត្ត តើមែនទេ ?<br>• តើរឿងនេះវាមិនរឹតតែធ្វើឱ្យអ្នកកាន់តែព្រួយបា<br>• រម្ភថែមទៀតទេឬយ៉ាងដូចម្តេច ?<br>• ។ល។ | • ដើម្បីឱ្យអ្នកឆ្លើយសំណួរធ្វើការឆ្លុះបញ្ចាំងឡើងវិញនូវគំនិត និងអារម្មណ៏របស់ខ្លួន ។ |
| • **សំណួរជីក** | • ក្រៅពីអ្វីដែលអ្នកបាននិយាយ តើនៅមានអ្វីទៀតដែលមើលទៅហាក់ដូចជានៅតែជាបញ្ហាសំរាប់អ្នក ?<br>• តើអ្នកនឹងអនុវត្តចំណេះដឹងទាំងនេះយ៉ាងដូចម្តេចនៅក្នុងការងាររបស់អ្នក ?<br>• តើមានអ្វីខ្លះជាកត្តាដែលមានឥទ្ធិពលដល់ការសំរេចចិត្តរបស់អ្នក ?<br>• ។ល។ | • ដើម្បីទាញចេញនូវចំណុច ឬកត្តាពាក់ព័ន្ធលំអិតទៅនឹងប្រធានបទនៃការពិភាក្សា ។<br>• ដើម្បីស្វែងយល់ពីតម្រូវការដែលបង្កប់នៅពីក្រោយគំនិតយោបល់ដែលបានលើកឡើងនោះ ។ |
| • **សំណួរនាំមុខ** | • តើអ្នកមិនគិតថាយោបល់នេះបង្ហាញពីទស្សនៈខ្លីៗចំពោះមុខទេឬ ?<br>• តើអ្នកមិនគិតថា ការនេះវានឹងរឹតតែធ្វើឱ្យបញ្ហាកាន់តែស្មុគ្រស្មាញឡើងទេឬ ?<br>• ។ល។ | • ដើម្បីនាំអ្នកឆ្លើយឱ្យទៅដល់គោលដៅមួយដែលអ្នកសួរចង់ទៅ ឬយល់ស្របតាមគំនិតរបស់អ្នកសួរ ។<br>• ដើម្បីឱ្យអ្នកឆ្លើយយល់ស្របតាមទស្សនៈរបស់អ្នកសួរ ។ |

ទោះបីជាយ៉ាងណាក៏ដោយ ការសួរសំណួរគឺជាជំនាញមួយដែលត្រូវការបទពិសោធន៏ និងចំណាយពេលដើម្បីហ្វឹកហាត់ ។ ប៉ុន្តែ នៅពេលដែលយើងមានបទពិសោធន៏ក្នុងការសួរ វានឹងបង្កើតបាននូវទំលាប់មួយដែលទំលាប់ខ្លះជាទំលាប់មិនសូវល្អ ។ តារាងខាងក្រោមនេះ នឹងពន្យល់បន្ថែមអំពីគំនិតនេះ ។

| ជំនួសឱ្យការសួរបែបនេះ ... | ព្យាយាមសួរបែបនេះវិញ ... | ដើម្បី ... |
|---|---|---|
| ១, តើអ្នកយល់កិច្ចការនេះឬទេ ? | ១, តើខ្ញុំពន្យល់កិច្ចការដែលត្រូវ ធ្វើនេះច្បាស់លាស់ដែរឬទេ ? | ***បង្ហាញថា ការទទួលខុសត្រូវ គឺស្ថិតនៅលើគ្រូ មិនមែនសិក្ខាកាមទេ*** |
| ២, តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ឱ្យនូវផ្ទាំងក្រដាសធំសំរាប់ការបង្រៀននេះ? | ២, តើយើងអាចទៅរកផ្ទាំងក្រដាសធំបន្ថែមទៀតនៅឯណាបាន ? | ***ផ្តោតការយកចិត្តទុកដាក់ទៅលើការដោះស្រាយបញ្ហា ជាជាងការស្តីបន្ទោស ។*** |
| ៣, ហេតុអ្វីបានជាអ្នកមានអារម្មណ៍កើតទុក្ខខ្លាំងម្លេះ ? | ៣, តើស្ថានភាពវាបានប្រែប្រួលទៅជាយ៉ាងណាទៅហើយមកដល់ពេលនេះ ? | ***លើកទឹកចិត្ត ជាជាងបន្ទុចបង្អាក់ ចំពោះអ្នកឆ្លើយក្នុងការឆ្លើយ ។*** |
| ៤, យើងសឹងតែនឹងបានបញ្ចប់ទៅហើយ មិនអញ្ចឹងឬ ? | ៤, តើអ្នកគិតថាគំរោងរបស់យើងបានអនុវត្តមកដល់ត្រឹមណាហើយឥឡូវនេះ ? | ***ចៀសវាងការបង្ខំឱ្យគេយល់ស្រប តាមរយៈការប្រើពាក្យ ( មិនអញ្ចឹងឬ ?) ដែលហាក់ដូចជាជំរុញឱ្យអ្នកស្តាប់ត្រូវតែយល់ព្រមតាម ។*** |
| ៥, ហេតុអ្វីបានជាអ្នកឈប់នៅត្រឹមនេះម្តេចមិនបញ្ចប់វាឱ្យហើយទៅ ? | ៥, តើមានអ្វីកើតឡើងចំពោះអ្នកទើបបានជាធ្វើឱ្យអ្នកឈប់នៅត្រឹមនេះ ? | ***ឱ្យអ្នកឆ្លើយមិនមានអារម្មណ៍ថាខ្លួនមានសម្ពាធត្រូវខំប្រឹងប្រែងស្វែងរកហេតុផលមកអះអាង ។ ជាជំនួសវិញ អ្នកឆ្លើយអាចពណ៌នាតាមសំរួលនូវ អ្វីដែលបានកើតឡើងចំពោះខ្លួនប្រាប់ដល់អ្នកសួរ ។*** |
| ៦, តើអ្នកមានទិន្នន័យ ឬព័ត៌មានអ្វីខ្លះក្នុងការគាំទ្រគំនិតរបស់អ្នក ? | ៦, សូមអ្នកប្រាប់ខ្ញុំបន្ថែមទៀត ! តើមានអ្នកណាបានស្រាវជ្រាវរឿង នេះដែរឬទេ ? | ***ចៀសវាងការបង្ខិតបង្ខំអ្នកស្តាប់ឱ្យខំរកហេតុផលការពារភាពកំសោយរបស់ខ្លួន ។*** |
| ៧, តើរឿងនេះអាចនឹងមានការផ្លាស់ប្តូរដូចម្តេចខ្លះនៅក្នុងអនាគតដែលយើងអាចប្រមើលមើលឃើញ ? | ៧, ដោយយោងតាមស្ថានភាពធនធានមនុស្សដែលអ្នកកំពុងមាន តើអ្នកគិតថារឿងនេះវានឹងអាចប្រែ ប្រួលទៅជាយ៉ាងដូចម្តេច ទៀតក្នុងរយៈពេល ៦ | ***បញ្ជាក់ឱ្យកាន់តែច្បាស់អំពីរយៈពេលក្នុងអនាគត ជាការងាយស្រួលដល់អ្នកឆ្លើយធ្វើការប៉ាន់ប្រមាណក្នុងការឆ្លើយសំណួរ ។*** |

| | | |
|---|---|---|
| | ខែខាងមុខ នេះ ? | |
| ៨. តើងគោលបំណងមួយណាដែលសំខាន់ជាងគេក្នុងចំណោមគោលបំណងទាំងអស់នេះ ? | ៨. តើសំណួរអ្វីដែលអ្នកគិតថាចង់បានចម្លើយជាចាំបាច់បំផុតនៅចុងបញ្ចប់នៃមេរៀននេះ ? | ***ផ្តោតការយកចិត្តទុកដាក់ទៅលើតម្រូវការរៀនសូត្រជាក់លាក់របស់សិក្ខា កាម និងជាការបង្ហាញថាអ្នកទទួលស្គាល់ និងផ្តល់តម្លៃដល់បញ្ហា ឬតម្រូវការ រៀនសូត្ររបស់អ្នកចូលរួមថាជារឿងសំខាន់ ។*** |

## ១០. ការសង្កេត

### និយមន័យ

ការសេង្កតគឺជាការតាមពិនិត្យមើលនូវសកម្មភាព ឬព្រឹត្តិការណ៍អ្វីមួយដោយយកចិត្តទុកដាក់ ក្នុងរយៈពេលជាក់លាក់ណាមួយ ដើម្បីរៀនសូត្រដកពិសោធន៍ និងកត់ត្រាចំណាំទុក ។

### ការសង្កេតនាំមកនូវទិន្ន័យ ២ យ៉ាងគឺ :

- **ទិន្ន័យជាការពិត**

  ឧទាហរណ៍ដូចជា :

  - ស្ថានភាព ឬលក្ខ័ខ័ណ្ឌដែលកំពុងមាន នៅក្នុងបរិបទនៃការងារជាក់លាក់ណាមួយ
  - ចំនួនមនុស្ស ( ប្រុស ស្រី ជនពិកា ក្មេង ចាស់ ។ល។ )
  - ទំហំនៃក្រុម ( ធំ ឬតូច )

- **ទិន្ន័យជាយោបល់**

  ឧទាហរណ៍ដូចជា :

  - ប្រតិកម្មតបរបស់អ្នកចូលរួម
  - អារម្មណ៍
  - កិរិតនៃការចូលរួម
  - គុណភាព

បន្ទាប់ពី ទទួលបាននូវទិន្ន័យទាំងពីរប្រភេទនេះហើយ អ្នកសំរបសំរួល/គ្រូបណ្តុះបណ្តាលគួរតែដឹងថាខ្លួនត្រូវធ្វើអ្វីជាជំងហានបន្ទាប់ នៅក្នុងការបង្រៀនមេរៀន ឬវគ្គទាំងមូលរបស់ខ្លួន ។ វាជាមូលដ្ឋានដ៏សំខាន់សំរាប់ឱ្យគ្រូបណ្តុះបណ្តាល ឬអ្នកសំរបសំរួលធ្វើការសំរេចចិត្តក្នុងការបត់បែន ។

## ១១, ជំនាញសំរាប់ធ្វើសេចក្តីសន្និដ្ឋាន

### ក- និយមន័យ

| ភាពខុសគ្នារវាងសេចក្តីសន្និដ្ឋាន និង ការសង្ខេប | |
|---|---|
| **ការសង្ខេប** | **ការសន្និដ្ឋាន** |
| **និយមន័យ** | |
| ជាការថ្លែងដោយសង្ខេបខ្លីអំពីរឿងរ៉ាវអ្វីមួយ | ជាការសំរេចចិត្តអំពីរឿងរ៉ាវអ្វីមួយបន្ទាប់ពីបានពិចារណា គ្រប់ពតិមានទាំងអស់ |
| **គោលបំណង** | |
| • ដើម្បីរៀបរាប់ឡើងវិញ ឬបញ្ជាក់ឱ្យឃើញច្បាស់ អំពីចំណុចសំខាន់ៗ<br>• ដើម្បីសន្សំពេលវេលាសំរាប់អ្នកអាន<br>• ដើម្បីច្រោះយកពតិមានដែលមិនសំខាន់ និង មិនចាំ បាច់ចេញ<br>• ដើម្បីធ្វើឱ្យអ្នកអានចាប់អារម្មណ៍<br>• ដើម្បីបង្ហាញនូវអ្វីដែលអ្នកនិពន្ធចង់ឱ្យអ្នកអាចដឹង អំពីអ្វីមួយ | • ដើម្បីបញ្ចប់នូវឯកសារឱ្យបានល្អត្រឹមត្រូវ<br>• ដើម្បីចែករំលែក ស្នើសុំ ផ្តល់នូវជំនឿ ឬយោបល់ ឬ សំណូមពរប្រកបដោយហេតុផល |

### ខ- វិធីសាស្រ្តមួយចំនួនសំរាប់ធ្វើសេចក្តីសន្និដ្ឋាន

ការសន្និដ្ឋានត្រូវបានធ្វើឡើងបន្ទាប់ពីក្រុមតូចៗបង្ហាញអំពីលទ្ធផលនៃការពិភាក្សារបស់ក្រុមដើម្បីផ្តល់ឱ្យអ្នករៀន មើលឃើញនូវអ្វីដែលជាក់ស្តែង ។

ការធ្វើសន្និដ្ឋានគេអាចមានវិធីជាច្រើនដើម្បីធ្វើវាដែលគេធ្វើទៅតាមរបៀបផ្សេងៗគ្នាទៅតាមប្រធានបទដែលពិភាក្សា ឬស្ថានភាព ។

សូមអ្នកពិចារណានូវគំនិតមួយចំនួនជាជំនួយសំរាប់ធ្វើសេចក្តី សន្និដ្ឋានដូចខាងក្រោមនេះ :

- ចាត់ជាក្រុមនូវគំនិតដែលដូចគ្នា និង មិនដូចគ្នាឱ្យដាច់ពីគ្នា
- ចាត់ជាថ្នាក់ ឬក្រុមនូវគំនិតដែលជាប់ទាក់ទង និង គំនិតដែលមិនជាប់ទាក់ទងនឹងសំនួរឬប្រធានបទដែលពិភាក្សា
- កំណត់ប្រធានបទដែលនៅពីក្រោមទៅតាមអ្វីដែលបានកើតឡើង
- ចាត់ជាក្រុម ឬប្រភេទចំលើយជាក់លាក់ទៅតាមក្រុម ឬ ប្រភេទចំលើយរបស់អ្នកបណ្តុះបណ្តាល ឬអ្នកសំរប សំរួលដែលបានកំណត់ទុកជាមុន ។
- គូរបន្ទាប់ក្រោម ឬពន្យល់នូវមូលហេតុ និង ឥទ្ធិពលដែលមានទំនាក់ទំនងទៅនឹងអ្វីមួយជាក់លាក់
- សុំឱ្យសិក្ខាកាមម្នាក់ៗជ្រើសរើសនូវគំនិតមួយចំនួនដែលគេប្រមើលមើលឃើញថា អាចអនុវត្តន៍បាននៅកន្លែង ធ្វើការ ឬស្ថានភាពរបស់គេ